ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកំពង់ធំ
លេខ: ១ជ១/២១ ស.ស.

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារគណនេយ្យភាពសង្គមថ្នាក់ខេត្ត

### អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០១៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ការកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ១៨២ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យលេខ ១៨៣ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ នៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- បានឃើញអនុក្រឹត្យលេខ ១៩៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីការប្រគល់មុខងារគ្រប់គ្រង និងការផ្តល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត
- យោងលិខិតលេខ៥២៩ ល.ស/គ.ជ.អ.ប ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៦ របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
- យោងកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងផែនការអនុវត្តន៍បីឆ្នាំជំណាក់កាលទី៣ (២០១៨-២០២០) នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប) ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៧

- យោងផែនការយុទ្ធសាស្ត្រ ស្តីពីការងារគណនេយ្យភាពសង្គមសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៣
- យោងផែនការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ឆ្នាំ២០១៦-២០១៨ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៦
- យោងផែនការអនុវត្តគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០១៩-២០២៣) ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៩
- យោងលិខិតលេខ ០៤០ សជណ/គ.ជ.អ.ប ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០២០ របស់គណៈកម្មាធិការជាតិ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ស្តីពីការបន្តអនុវត្តផែនការយុទ្ធសាស្ត្រ ការងារគណនេយ្យភាពសង្គម នៅថ្នាក់ក្រុង ស្រុក ខណ្ឌគោលដៅ នៃការផ្តល់សេវា(រដ្ឋបាលឃុំ រដ្ឋបាលសង្កាត់ សាលាបឋមសិក្សា និងការផ្តល់សេវានៅមណ្ឌលសុខភាព) និងផែនការអនុវត្តគណនេយ្យភាពសង្គម ដំណាក់កាលទី២ នៅថ្នាក់រដ្ឋបាលក្រុង រដ្ឋបាលស្រុក និងរដ្ឋបាលខណ្ឌនៃរាជធានី ខេត្ត
- យោងតាមការចាំបាច់របស់រដ្ឋបាលខេត្ត

## សម្រេច

**ប្រការ ១.**_

ត្រូវបានបង្កើតក្រុមការងារគណនេយ្យភាពសង្គមថ្នាក់ខេត្ត ដូចខាងក្រោម៖

| | | |
|---|---|---|
| ១-លោកជំទាវ **លំ គន្ធារី** | អភិបាលរងខេត្ត | ជាប្រធាន |
| ២-លោក **សុិន ឫណ្ណឫទ្ឋ** | នាយករងរដ្ឋបាលខេត្ត | អនុប្រធាន |
| ៣-លោក **ស្រី សុីន** | ប្រធានមន្ទីរសុខាភិបាល | សមាជិក |
| ៤-លោក **តាន់ ប៊ុនហុង** | ប្រធានមន្ទីរអប់រំ យុវជន និងកីឡា | សមាជិក |
| ៥-លោក **សុខ សុផល** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៦-លោក **ពត សាន** | ប្រធានរតនាគារ | សមាជិក |
| ៧-លោក **លី ឫេត** | នាយកទីចាត់ការផែនការ និងវិនិយោគ | សមាជិក |
| ៨-លោក **សួត៌ ច័ន្ទតារា** | នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស | សមាជិក |
| ៩-លោក **លី ហ្គាលី** | នាយកទីចាត់ការអន្តរវិស័យ | សមាជិក |
| ១០-លោកស្រី **ឆន ស៊ូតាង** | នាយិកាទីចាត់ការហិរញ្ញវត្ថុ | សមាជិក |
| ១១-លោកស្រី **ឡៀម សុខឃីម** | នាយិការងទីចាត់ការហិរញ្ញវត្ថុ | សមាជិក |
| ១២-លោក **ហេង សូលីឌីន** | នាយករងទីចាត់ការគ្រប់គ្រងធនធានមនុស្ស | សមាជិក |
| ១៣-លោក **ឫីហាន សីលា** | មន្ត្រីបង្គោលគណនេយ្យភាពសង្គមខេត្ត | សមាជិកអចិន្ត្រៃយ៍ |
| ១៤-លោក **អភិបាលក្រុង ស្រុក** | | សមាជិក |
| ១៥-លោក **ស៊ុន រដ្ឋេ** | ប្រធានការិយាល័យគាំទ្រមូលដ្ឋាន | សមាជិក |
| ១៦-លោកស្រី **ឈួន សោតា** | អនុប្រធានការិយាល័យគណនេយ្យ | សមាជិក |
| ១៧-លោក **កែ ឌីឫ័ន្ត** | អនុប្រធានការិយាល័យសរុបនិងព័ត៌មាន | សមាជិក |
| ១៨-លោក **អ៊ឹម សុឃាន់** | អនុប្រធានការិយាល័យកសាងសមត្ថភាព | សមាជិក |
| ១៩-តំណាងអង្គការមិនមែនរដ្ឋាភិបាល ដៃគូអនុវត្តការងារគណនេយ្យភាពសង្គម | | សមាជិក |

**ប្រការ ២._**

**ក្រុមការងារគណនេយ្យភាពសង្គមរដ្ឋបាលខេត្តកំពង់ធំ មានតួនាទីភារកិច្ចដូចខាង ក្រោម៖**

-គាំទ្ររដ្ឋបាលខេត្ត ក្នុងការអភិវឌ្ឍសមត្ថភាព ពាក់ព័ន្ធនឹងការអនុវត្តការងារគណនេយ្យភាពសង្គមដល់រដ្ឋបាលខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ មន្ត្រីបង្គោលគណនេយ្យភាពសង្គមខេត្ត ក្រុង ស្រុក ឃុំ សង្កាត់ ស្ថាប័ន ពាក់ព័ន្ធ (មន្ទីរអប់រំ យុវជន និងកីឡាខេត្ត មន្ទីរសុខាភិបាល ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក និងការិយាល័យសុខាភិបាលស្រុកប្រតិបត្តិ)

-គាំទ្រការអនុវត្តទាំងផ្នែកផ្គត់ផ្គង់(តួអង្គរដ្ឋ) និងផ្នែកតម្រូវការ ប្រជាពលរដ្ឋ អង្គការសង្គមស៊ីវិល តាមគោលការណ៍ណែនាំនានា នៃផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

-សម្របសម្រួលការងារទូទៅជាមួយស្ថាប័ន មន្ទីរ អង្គភាព និងមន្ត្រីដៃគូអនុវត្តនៅមូលដ្ឋាន

-គាំទ្រការរៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ សម្រាប់ការងារគណនេយ្យភាពសង្គម

-រៀបចំរបាយការណ៍ជាប្រចាំជូនថ្នាក់ដឹកនាំ និងរៀបចំរបាយការណ៍ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្តីពីវឌ្ឍភាព និងបញ្ហាប្រឈមនានាការអនុវត្តការងារគណនេយ្យភាពសង្គម ជូនថ្នាក់ដឹកនាំសម្រាប់រាយការណ៍ និងក្នុងកិច្ចប្រជុំក្រុមប្រឹក្សានៅក្នុងពេលអនុវត្ត ព្រមទាំងសម្របសម្រួលរវាងផ្នែកផ្គត់ផ្គង់ និងផ្នែកតម្រូវការ

-រៀបចំរបាយការណ៍ឆមាស និងប្រចាំឆ្នាំ ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម ជូនលេខាធិការដ្ឋាន គ.ជ.អ.ប

-តាមដាន ត្រួតពិនិត្យ និងចូលរួមក្នុងការអនុវត្តសកម្មភាពគណនេយ្យភាពសង្គម នៅក្រុង ស្រុក ឃុំ សង្កាត់

-រៀបចំប្រជុំទៀងទាត់នូវរាល់ត្រីមាស ឆមាស និងប្រចាំឆ្នាំ ស្តីពីការអនុវត្តការងារគណនេយ្យភាពសង្គម

-អនុវត្តតួនាទីភារកិច្ចផ្សេងៗទៀត ពាក់ព័ន្ធនឹងការងារគណនេយ្យភាពសង្គម ដែលថ្នាក់ដឹកនាំប្រគល់ជូន

**ប្រការ ៣._**

អភិបាលរង នាយករងរដ្ឋបាលខេត្ត ប្រធានមន្ទីរ អង្គភាពជំនាញ នាយកទីចាត់ការ នាយិកាទីចាត់ការ និងប្រធានអង្គភាពចំណុះរដ្ឋបាលខេត្ត អភិបាលក្រុង ស្រុក និងលោកជំទាវ អស់លោក លោកស្រីដែលមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៦ លាច ខែ សីហា ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

កំពង់ធំ ថ្ងៃទី ៤៧ ខែ តុលា ឆ្នាំ២០២១

**អភិបាល**

**ចម្លងជូន៖**

- ក្រសួងស្ថាប័នពាក់ព័ន្ធ
- លេខាធិការដ្ឋាន គ.ជ.អ.ប
- អង្គការសង្គមស៊ីវិល ដៃគូអនុវត្ត "ដើម្បីជូនជ្រាប"
- ប្រការ១ និងប្រការ៣ "ដើម្បីសហការអនុវត្ត"
- ឯកសារ កាលប្បវត្តិ

ឡន រតនៈ